នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-May-2020, 14:49
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី មាស មុត**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៣ ទាំងអស់**

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សុំឆ្លើយតបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សារណាបន្ថែមទៅលើបណ្តឹងឧទ្ធរណ៍")[1]។ សម្រាប់មូលហេតុដូចបានរៀបរាប់លម្អិតខាងក្រោម ស.ព.អ យល់ឃើញថា សារណាបន្ថែមទៅលើបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។ វាមិនមានមូលដ្ឋានត្រឹមត្រូវ និងមិនត្រូវតាមពេលវេលា ហើយការទទួលយកវានឹងមិនបានការពារដល់សិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ មាស មុត នោះទេ។ គាត់ក៏ជំទាស់ទៅនឹងសំណើរបស់ មាស មុត សុំឲ្យមានសវនាការផ្ទាល់មាត់ផងដែរ[2]។

2. អំណះអំណាងរបស់វាលើអង្គសេចក្តីក៏ខុសដូចគ្នាដែរ។ ការអះអាងរបស់ មាស មុត ថា ការចេញដោយខុសច្បាប់នៃដីកាដំណោះស្រាយពីរខ្វែងគ្នានេះបានធ្វើឲ្យដីកាទាំងពីរទៅជាមោឃៈនោះ គឺមិនត្រឹមត្រូវឡើយ ដោយសារតែមានការយល់ច្រឡំ*ជាអាទិ៍* អំពីសេចក្តីពិចារណានៃរឿងក្តី ០០៤/២ របស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") និងការបកស្រាយខុសនូវវិធាន[3] ៦៧(២) និង ៧៦ នៃវិធានផ្ទៃក្នុង។ ក្នុងការស្នើសុំឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីនៃរឿងក្តី ០០៣ ជាអចិន្ត្រៃយ៍នោះ មាស មុត ស្វែងរកដំណោះស្រាយដ៏គំហុកមួយក្នុងចំណោមដំណោះស្រាយនានា ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានដឹង ផ្អែកលើមូលដ្ឋាននៃការវិភាគខុសអំពីច្បាប់ ដែលលាយឡំជាមួយការស្មានជាច្រើន។

## II. ប្រវត្តិនីតិវិធី និងច្បាប់ជាធរមាន

3. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដោយចោទប្រកាន់ មាស មុត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា

---

[1] ឯកសារ **D267/27** សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ (បណ្តឹងឧទ្ធរណ៍បន្ថែម) បានជូនដំណឹងជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០។

[2] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម ទំព័រ ១។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដូចដែលបានពិនិត្យឡើងវិញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

ទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឲ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[4]។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយទម្លាក់រាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង មាស មុត ដោយផ្អែកលើមូលដ្ឋានថា គាត់មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[5]។

4. បណ្តឹងឧទ្ធរណ៍ចំនួនបីបានដាក់៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានប្តឹងឧទ្ធរណ៍ដោយសហព្រះរាជអាជ្ញាជាតិ[6] ហើយ មាស មុត បានដាក់បណ្តឹងឧទ្ធរណ៍មួយ ដោយស្នើសុំឲ្យលើកលែងចោទប្រកាន់ចំពោះរឿងក្តីនេះ ប្រសិនបើ អ.ប.ជ មិនបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់ និងមិនតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមរយៈសំឡេងភាគច្រើនលើសលុប ទេនោះ[7]។ អតីត ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍មួយជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់[8]។ ភាគីនានាបានដាក់ចម្លើយតប និងការឆ្លើយតបរបស់ពួកគេរៀងៗខ្លួន ត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩[9]។ សវនាការផ្ទាល់មាត់បានធ្វើឡើងនៅចន្លោះថ្ងៃទី២៧ និង ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩[10]។ ក្រោយមក អ.ប.ជ បានបិទបញ្ចប់កិច្ចដំណើរការនីតិវិធីសម្រាប់ការប្រជុំពិភាក្សា។

---

[4] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ទំព័រ ២៥៦-២៦៤។

[5] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ទំព័រ ៤២៧-៤៣០។

[6] ឯកសារ **D267/3** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

[7] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត")។

[8] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")។

[9] **<u>ចម្លើយតប៖</u>** ឯកសារ **D267/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។ ឯកសារ **D267/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត")។ ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។ **<u>ការឆ្លើយតប:</u>** ឯកសារ **D266/6** & ឯកសារ **D267/11** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ("ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍")។ ឯកសារ **D266/7** & ឯកសារ **D267/12** ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះ

5. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ មាស មុត បានដាក់សំណើរបស់ខ្លួនសុំការបញ្ជាក់បំភ្លឺ[11] អំពីសេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២[12] ដែល ស.ព.អ បានឆ្លើយតបទៅនឹងសំណើនេះ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០[13]។ មាស មុត បានធ្វើការឆ្លើយតបនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០[14]។ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ស.ច.ស.អ Michael Bohlander ត្រូវបានបន្តតំណែងឡើងវិញដើម្បីមកធ្វើការជាមួយសហការីកម្ពុជារបស់គាត់ គឺចៅក្រម យូ ប៊ុនឡេង[15]។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ អ.ប.ជ បានអនុញ្ញាតតាមសំណើសុំរបស់ ស.ព.អ ដាក់ចម្លើយតបរបស់ខ្លួនមិនឲ្យហួសថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២០[16]។

6. អ.ប.ជ រំពឹងថា នឹងចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ភាគី នៅក្នុងត្រីមាសទីបីនៃឆ្នាំ២០២០ នេះ[17]។

---

រាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។

[10] ពង្រាងប្រតិចារឹកនៃសវនាការរបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។ ពង្រាងប្រតិចារឹកនៃសវនាការរបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ ឯកសារ **D266/18.2** & **D267/23.2** ប្រតិចារឹក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

[11] ឯកសារ **D266/19** & **D267/24** សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/២,ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០("សំណើសុំការបញ្ជាក់បំភ្លឺ")។

[12] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណាលើសំណុំរឿង ០០៤/២")។

[13] ឯកសារ **D266/20** & **D267/25** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ("ចម្លើយតបរបស់ ស.ព.អ អំពីការបញ្ជាក់បំភ្លឺ")។

[14] ឯកសារ **D266/21** & **D267/26** ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសំណោះស្រាយក្នុងរឿងក្តី០០៤/២ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០។

[15] សេចក្តីថ្លែងការណ៍របស់ អ.វ.ត.ក៖ *ការបន្តតំណែងឡើងវិញចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។

[16] សារអេឡិចត្រូនិចពីក្រឡាបញ្ជីអ.ប.ជ Hyuree Kim ក្រោមចំណងជើងថា"សេចក្តីជូនដំណឹងរបស់ អ.ប.ជ អំពីការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាដើម្បីឆ្លើយតបទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ នៅម៉ោង ២:៥៩ នាទីរសៀល។

[17] ផែនការបញ្ចប់ វិសោធនកម្មលើកទី២៤ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ១១(ក), ១៣(ii), ២៥(ខ)។

## *សំណុំរឿង ០០៤/២*

7. ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៤/២[18]។ ក្រោយពីសម្រេចជាឯកច្ឆ័ន្ទថា *ការចេញ* ដីកាដំណោះស្រាយពីរខ្វែងគ្នាខុសច្បាប់រួចមក[19] បន្ទាប់មក ចៅក្រមមិនបានច្រានចោលដីកាដំណោះស្រាយសំណុំរឿង ០០៤/២ ទាំងពីរនេះទេ។ ផ្ទុយទៅវិញ ពួកគាត់បានពិចារណាលើនីត្យានុកូលភាពនៃដីកាដំណោះស្រាយ*នីមួយៗ* ដោយឈានទៅដល់ការសន្និដ្ឋានផ្សេងគ្នាលើឋានៈផ្លូវច្បាប់ដាច់ដោយឡែកពីគ្នានៃដីកាពីរទាំងនោះ[20]។ អ.ប.ជ បរាជ័យមិនបានឈានទៅដល់សេចក្តីសម្រេចមួយដែលមានសំឡេងភាគច្រើនលើសលុប ដើម្បីបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងរឿងក្តីនោះទេ។

8. ចាប់តាំងពីការចេញសេចក្តីពិចារណាទាំងអស់នោះមក ភាគីនានានៃសំណុំរឿង ០០៤/២ បានដាក់ញត្តិជាច្រើនទៅកាន់ អ.ប.ជ អង្គជំនុំជម្រះសាលាដំបូង (“អ.ជ.ស.ដ”)[21] និងការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”)។ ស.ព.អ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះបានប្តឹងជាស្វ័យប្រវត្តិទៅ អ.ជ.ស.ដ តាមវិធាន ៧៧(១៣)(ខ) និងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ ស.ព.អ ដោយមានការគាំទ្រពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើឱ្យ អ.ប.ជ បំពេញកិច្ចការ*រដ្ឋបាល* ដែលនៅសេសសល់ក្នុងការបញ្ជូនសំណុំរឿង ០០៤/២ ទៅកាន់ អ.ជ.ស.ដ សម្រាប់ការជំនុំ

---

[18] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២។

[19] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៥៤, ៨៩, ៩៨, ១០២, ១២៤, ផ្នែកសម្រេចសេចក្តី, EN 01634239 (ជាឯកច្ឆ័ន្ទ)។

[20] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៨៩, ១២៤ (ជាឯកច្ឆ័ន្ទ)។ មតិយោបល់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហ៊ួត វុទ្ធី (“មតិយោបល់ចៅក្រមជាតិ”), កថាខណ្ឌ ១៧០-៣០២ មតិយោបល់របស់ចៅក្រម Baik និង Beauvallet (“មតិយោបល់របស់ចៅក្រមអន្តរជាតិ”), កថាខណ្ឌ ៣០៤-៣២៩, ៦៨១។

[21] ការដាក់ឯកសាររបស់ភាគីនានាក្នុងសំណុំរឿង០០៤/២ ជូនទៅ អ.ជ.ត.ក ត្រូវបានរៀបរាប់យ៉ាងពិស្តារនៅក្នុងសំណុំរឿង ០០៤/២-ឯកសារ **E004/2/1** បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលុតជាធរមាននៃសំណុំរឿង០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ (“បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ជូនទៅ អ.ជ.ត.ក”) កថាខណ្ឌ ៧-១១, ១៤, ១៩, ២២-២៣, ២៨។

ជម្រះ[22]។ ក្រុមមេធាវីការពារក្តី អោ អាន បានស្វែងរកឱ្យមានការរក្សាសំណុំរឿង ០០៤/២ នេះទុកក្នុងបណ្ណសារ ផ្អែកលើមូលដ្ឋានថា រឿងក្តីនេះបានទម្លាក់ការចោទប្រកាន់ហើយ[23]។

9. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ និងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានផ្ញើរសារអេឡិចត្រូនិកមួយទៅកាន់ភាគីនានានៃសំណុំរឿង ០០៤/២ និងចៅក្រម អ.ប.ជ ដោយបានលើកឡើងថា សេចក្តីពិចារណារបស់ អ.ប.ជ មិនបានជូនដំណឹងជាផ្លូវការមកកាន់ អ.ជ.ស.ដ ទេ ហើយសំណុំរឿង និងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏មិនទាន់បញ្ជូនមកដែរ។ សារអេឡិចត្រូនិកទីពីរបានសន្និដ្ឋានថា អ.ប.ជ ត្រូវផ្តួចផ្តើមសកម្មភាពទាំងអស់នោះ[24]។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik បានចេញអនុស្សរណៈអន្តរការិយា

---

[22] **<u>ស.ព.អៈ</u>** សំណុំរឿង០០៤/២-ឯកសារ **D359/25** & **D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿង០០៤/២-ឯកសារ **D359/28** & **D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង០០៤/២-ឯកសារ **D359/30** & **D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។ សំណុំរឿង០០៤/២-ឯកសារ **D363/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។ **<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**ៈ សំណុំរឿង០០៤/២-ឯកសារ **D359/33** & **D360/42** សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

[23] សំណុំរឿង០០៤/២-ឯកសារ **D359/27** & ឯកសារ **D360/36** សំណើ [របស់ អោ អាន] សុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង០០៤/០២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿង០០៤/២-ឯកសារ **D363** សំណើ[របស់ អោ អាន] សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។ *សូមមើលផងដែរ* សំណុំរឿង០០៤/២-ឯកសារ **D359/26** & ឯកសារ **D360/35** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿង០០៤/២-ឯកសារ **D359/31** & ឯកសារ **D360/40** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[24] សំណុំរឿង០០៤/២-ឯកសារ **D359/36.2** & **D360/45.2** សារអេឡិចត្រូនិចពីក្រឡាបញ្ជី អ.ជ.ស.ដ លឹម ស៊ុយហុង មានចំណងជើងថា ៖ “ព័ត៌មាន” ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ នៅម៉ោង ១.០០ នាទី រសៀល។ សំណុំរឿង០០៤/២-ឯកសារ **D359/36.8** & **D360/45.8** សារអេឡិចត្រូនិចពីក្រឡាបញ្ជី អ.ជ.ស.ដ លឹម ស៊ុយហុង មានចំណងជើងថាៈ “ទាក់ទងនឹងសំណើរបស់ ស.ព.អ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០” ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ១១.៤៤នាទី ព្រឹក។

ល័យមួយ ដែលបានរៀបរាប់អំពីវិធានការដែលពួកគាត់បានចាត់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ នេះទៅកាន់ អ.ជ.ស.ដ ដែលតាមទស្សនៈរបស់ពួកគេ ត្រូវបានប្ដឹងឱ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្ដី ០០៤/២ នេះរួចទៅហើយ[25]។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធាន អ.ប.ជ គឺចៅក្រម ប្រាក់ គឹមសាន បានចេញអនុស្សរណៈមួយដោយបានលើកឡើងថា សេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ មិនបានអនុញ្ញាតឱ្យបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ ទេ[26]។ មកទល់កាលបរិច្ឆេទនៃការដាក់ឯកសារនេះ សំណុំរឿង ០០៤/២ មិនទាន់ត្រូវបានបញ្ជូនទៅកាន់ អ.ជ.ស.ដ នៅឡើយ។

10. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ចៅក្រម អ.ជ.ស.ដ បានចេញសេចក្ដីថ្លែងការណ៍មួយ (“សេចក្ដីថ្លែងការណ៍”) ដោយបានលើកឡើង*ជាអាទិ៍*ថា ការចេញសេចក្ដីសម្រេចផ្លូវការ “មិនអាចធ្វើបានទេ” ខ្លួនមិនមានសំណុំរឿង ០០៤/២ និងឯកសារពាក់ព័ន្ធ ហើយសំណើដែលបានដាក់ដោយភាគីនានាមកកាន់ អ.ជ.ស.ដ នឹងត្រូវបង្វិលត្រឡប់ទៅម្ចាស់ដើមវិញ[27]។

11. នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ស.ព.អ បានដាក់បណ្ដឹងសាទុក្ខជាបន្ទាន់ ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) ដោយបានសន្និដ្ឋានថា អ.ជ.ស.ដ មានកំហុសផ្នែកច្បាប់ និងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការរំលត់សំណុំរឿង ០០៤/២ ជាធរមាន ដែលបានបង្កឱ្យមានព្យសនកម្មដល់ ស.ព.អ និងភាគីផ្សេងទៀតនៃសំណុំរឿង ០០៤/២[28]។ បណ្ដឹងសាទុក្ខជាបន្ទាន់នេះ បច្ចុប្បន្ននៅចំពោះមុខ អ.ជ.ត.ក និងមិនទាន់ត្រូវបានសម្រេចនៅឡើយ គិតត្រឹមកាលបរិច្ឆេទនៃការដាក់ឯកសារនេះ។

12. ច្បាប់ជាធរមានត្រូវបានរៀបរាប់ខាងក្រោមត្រង់ចំណុចដែលពាក់ព័ន្ធ។

## III. **សារណា**

### ***<u>ភាពអាចទទួលយកបាន</u>***

---

[25] **D266/20.1.10** & **D267/25.1.10** សំណុំរឿង០០៤/២-អនុស្សរណៈអន្តរការិយាល័យ ពីចៅក្រម អ.ប.ជ, លោក Olivier Beauvallet និងលោក Kang Jin Baik, ក្រោមចំណងជើងថា “ការបញ្ជូនសំណុំរឿង០០៤/២” ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

[26] ឯកសារ **D266/20.1.11** & **D267/25.1.11** សំណុំរឿង០០៤/២-អនុស្សរណៈ ពីប្រធាន អ.ប.ជ, លោក ប្រាក់ គឹមសាន, ក្រោមចំណងជើងថា “ការបញ្ជាក់ឡើងវិញពីសេក្ដីសម្រេចលើសំណុំរឿង០០៤/២” ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

[27] សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងសំណុំរឿង០០៤/២ ទាក់ទងនឹង អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ (“សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ”)។

[28] សំណុំរឿង០០៤/២-ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ជូនទៅ អ.ជ.ត.ក។

13. ស.ព.អ សន្និដ្ឋានថា សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍ គឺមិនអាចទទួលយកបាន និងមិនត្រឹមត្រូវតាមពេលវេលាឡើយ។ តាមរយៈសំណើថ្មីៗរបស់គាត់សុំការបញ្ជាក់បំភ្លឺ[29] សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍នេះ បង្កើតបានជាការប៉ុនប៉ងខុសច្បាប់មួយផ្សេងទៀតក្នុងការបើកកិច្ចដំណើរការនីតិវិធីក្នុងរឿងក្ដី ០០៣ ឡើងវិញ។ ដូចដែល ស.ព.អ បានកត់សំគាល់នៅក្នុងចម្លើយតបរបស់គាត់ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺពីខាងដើមរួចហើយ[30] អ.ប.ជ បានបញ្ជាក់រួចមកហើយថា សេចក្ដីសន្និដ្ឋានជាលាសយលក្ខណ៍អក្សរលើបណ្ដឹងឧទ្ធរណ៍ក្នុងរឿងក្ដីនេះបានបញ្ចប់ហើយ[31] សវនាការផ្ទាល់មាត់បានធ្វើរួចហើយ[32] ហើយ អ.ប.ជ បានសម្រាកដើម្បីធ្វើការប្រជុំពិភាក្សា[33]។ វិធានមិនអនុញ្ញាតឱ្យមានអំណះអំណាងណាបន្ថែមទៀតពីភាគីក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះឡើយ។ ហេតុដូច្នេះ ប្រសិនបើ អ.ប.ជ *មិនស្វែងរក* សារណាពីភាគីនានានៃសំណុំរឿង ០០៣ លើបញ្ហាណាមួយបន្ថែមទៀតទេ ស.ព.អ សន្និដ្ឋានថា ភាគីត្រូវបានហាមឃាត់មិនឱ្យដាក់សារណាបន្ថែមទៀតទេ រួមទាំងសារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ផង។

14. ការពឹងផ្អែករបស់ មាស មុត លើការចេញសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ ដើម្បីជាយុត្តិកម្មនៃភាពអាចទទួលយកបានផ្អែកលើមូលដ្ឋានករណីពិសេសនោះ គឺមិនត្រឹមត្រូវដោយមូលហេតុពីរ។ ទីមួយ សេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ មិនមែនជា "ព័ត៌មានថ្មី" នោះទេ[34]។ យុត្តិសាស្ត្រថ្មី និង/ឬ ការវិវឌ្ឍន៍ផ្នែកនីតិវិធីនៅក្នុងរឿងក្ដីផ្សេងទៀត ដូចដែល មាស មុត បានតវ៉ា គឺមិនស្រដៀងគ្នាទៅនឹង "ព័ត៌មានថ្មី" តាមវិធាន ៨៧(៤) នោះទេ។ ដូចដែលគាត់បានរំលឹកខ្លួនឯងថា គោលបំណងនៃវិធាននោះ គឺដើម្បីអនុញ្ញាតឱ្យមានការទទួលយកភស្តុតាងនៅដំណាក់កាលជំនុំជម្រះដែល"ជួយដល់ការស្វែងរកការពិត"[35]។ វាមិនមែនដើម្បីអនុញ្ញាតឱ្យភាគីធ្វើសារណាជាច្រើនរាល់

---

[29] ឯកសារ **D266/19 & D267/24** សំណើសុំការបញ្ជាក់បំភ្លឺ។

[30] ឯកសារ **D266/20 & D267/25** ចម្លើយតបរបស់ ស.ព.អ អំពីការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១១។

[31] ឯកសារ **D266/12 & D267/17** ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ទំព័រ១។ នៅពេលដែលអានជាមួយគ្នា វិធាន ៧៧ នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៣ និង ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក គ្រោងទុកជាមុននូវ ចម្លើយតប និងការឆ្លើយតប ទៅនឹងបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ។ *សូមមើលបន្ថែមទៀត* ឯកសារ **D266/4 & D267/6** សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ចម្លើយតប និងការឆ្លើយតបនានា ទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយសំណុំរឿង០០៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩។

[32] *សូមមើលខាងលើ* កថាខណ្ឌ៥។

[33] វិធាន ៧៧(១២) នៃវិធានផ្ទៃក្នុង។

[34] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ ទំព័រ១ កថាខណ្ឌ ១។

[35] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១។

ពេលមានការវិវឌ្ឍន៍ពាក់ព័ន្ធដែលគេបានអះអាងថា បានកើតមានឡើងក្នុងរឿងក្តីផ្សេងទៀតនោះទេ។ រឿងក្តីស្មុកស្មាញ ដូចជារឿងក្តីទាំងនេះ ដែលក្នុងនោះមានបញ្ហាច្បាប់សារធាតុ និងនីតិវិធីពាក់ព័ន្ធរាប់រយ នឹងមិនត្រូវបានបញ្ចប់ឡើយ ដែលផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ និងសិទ្ធិផ្ទាល់ខ្លួនរបស់ មាស មុត ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីដ៏ឆាប់រហ័ស ប្រសិនបើវាជាការអនុវត្តទូទៅក្នុងការអនុញ្ញាតឱ្យភាគីដាក់សារណាបន្ថែម រាល់ពេលដែលមានយុត្តិសាស្ត្រថ្មី ឬ ការវិវឌ្ឍន៍ផ្នែកនីតិវិធីផ្សេងបានកើតឡើងនៅ អ.វ.ត.ក ឬតុលាការអន្តរជាតិ (មានលក្ខណៈអន្តរជាតិ) ផ្សេងទៀតនោះ។

15. មាស មុត បានសន្និដ្ឋានដោយគ្មានអង្គសេចក្តីថា សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ គួរត្រូវបានអនុញ្ញាតទទួលយកដើម្បីការពារ "សិទ្ធិរបស់ [គាត់] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌"[36]។ ទោះជាយ៉ាងណា មាស មុត ខកខានមិនបានពន្យល់ពីរបៀបដែលសិទ្ធិរបស់គាត់អាចទទួលរងព្យសនកម្ម នៅពេលដែល អ.ប.ជ អាចចូលមើល និងមានលទ្ធភាពធ្វើការវិភាគលើការវិវឌ្ឍន៍ពាក់ព័ន្ធក្នុងសំណុំរឿង ០០៤/២ រួមទាំងសេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ ដែលក្រឡាបញ្ជីរបស់ អ.ជ.ស.ដ បានផ្ញើតាមសារអេឡិចត្រូនិកទៅកាន់ភាគីនានា[37] និងបានដាក់ផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ អ.វ.ត.ក[38]។

16. ជាងនេះទៀត សារណាសំខាន់បំផុតនៃសារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនកើតចេញផ្ទាល់ពីសេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ នោះទេ ហើយការពិនិត្យឱ្យកាន់តែជិតដល់លើការដាក់ឯកសារពីមុនៗរបស់ មាស មុត បង្ហាញថា សារណាទាំងនោះតាមពិតមិន "ថ្មី" ចំពោះគាត់ទេ ដោយហេតុថា វាត្រូវបានចេញនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០។ ដូចដែល មាស មុត ទទួលស្គាល់[39] ការជំទាស់របស់គាត់ថា ដីកាដំណោះស្រាយទាំងពីរនៃសំណុំរឿង ០០៣ នឹងត្រូវ "ទុកជាមោឃៈ ឥតបានការ និងស្ថិតនៅក្រៅការត្រួតពិនិត្យដោយអង្គជំនុំជម្រះលើអង្គសេចក្តី

---

[36] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២។

[37] សេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ ត្រូវបានភ្ជាប់ទៅនឹងសារអេឡិចត្រូនិចពីក្រឡាបញ្ជី អ.ជ.ស.ដ លឹម ស៊ុយហុង ក្រោមចំណងជើងថា "សេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ម៉ោង៖ ១:៤៩នាទីរសៀល ហើយបានផ្ញើជូនទៅភាគីនានានៃសំណុំរឿង០០៤/២ និងគ្រប់ចៅក្រមទាំងប្រាំរូបនៃ អ.ប.ជ។

[38] អាចរកបានជាភាសាអង់គ្លេសនៅត្រង់ https://www. eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ចូលបើកមើលចុងក្រោយនៅកាលបរិច្ឆេទនៃការដាក់ឯកសារនេះ)។

[39] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។

នោះ”[40] កើតចេញពីការសម្រេចរបស់ អ.ប.ជ ក្នុងសេចក្ដីពិចារណានៃសំណុំរឿង០០៤/២ មិនមែនសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ នោះទេ ហើយតាមពិតនោះ ត្រូវបានបង្ហាញយ៉ាងជាក់ស្ដែងនៅក្នុងសំណើសុំការបញ្ជាក់បំភ្លឺរបស់ មាស មុត ថ្មីៗនេះ[41]។ ស្រដៀងគ្នានេះដែរ ខណៈដែលពេលនេះគាត់បានប្ដូរគោលជំហររបស់គាត់ ដោយសារសំណើសុំការបញ្ជាក់បំភ្លឺរបស់គាត់សម្រាប់មូលហេតុជាច្រើនដែលមិនពាក់ព័ន្ធទៅនឹងសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ[42] នោះចំណុចសំខាន់នៃអំណះអំណាងរបស់ មាស មុត ទាក់ទងនឹងការធានាឲ្យមានឧបាស្រ័យ ជាថ្មីម្ដងទៀតកើតចេញពីសេចក្ដីពិចារណានៃសំណុំរឿង ០០៤/២។ ដូច្នេះ ការយោងទៅលើសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ ទំនងជាការប៉ុនប៉ងបង្វែរចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះ ឲ្យងាកចេញពីបរាជ័យរបស់ មាស មុត ក្នុងការដាក់សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ រហូតដល់រយៈពេលជាងបួនខែក្រោយពេលបោះពុម្ពផ្សាយសេចក្ដីពិចារណានៃសំណុំរឿង ០០៤/២។

17. ពីមុន មាស មុត ធ្លាប់បានទទួលស្គាល់ថា - តាមរយៈសារណាជាលាយលក្ខណ៍អក្សរទៅកាន់ អ.ប.ជ និង អំណះអំណាងផ្ទាល់មាត់នៅចំពោះមុខ អ.ប.ជ[43] - គាត់ធ្លាប់ត្រូវបានផ្ដល់ និងបានទទួលយកឱកាសដើម្បីធ្វើការតវ៉ាអំពីខ្លឹមសារនៃបញ្ហា ដែលជាមូលដ្ឋាននៃសារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍នេះ ដែលវិវឌ្ឍន៍ជុំវិញភាពសមស្របនៃការចេញដីកាដំណោះស្រាយពីរ និងផលវិបាកលើអានុភាពផ្នែកច្បាប់នៃដីកាដំណោះស្រាយទាំងអស់នេះ និងអនាគតនៃរឿងក្ដី ០០៣។ សិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់គាត់ រួមទាំងសិទ្ធិធ្វើសវនាការលើបញ្ហាទាំងអស់នោះ និងទទួលបានការប្ដឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធិភាព ដូចដែលត្រូវបានធានានៅក្នុងកិច្ចព្រមព្រៀង

---

[40] ឯកសារ **D267/27** សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៥-៣២។

[41] ឯកសារ **D266/19 & D267/24** សំណើសុំការបញ្ជាក់បំភ្លឺ ទំព័រ១ កថាខណ្ឌ ១, ១៨-២១, ៣៤-៣៥។

[42] នៅក្នុងសំណើសុំការបញ្ជាក់បំភ្លឺរបស់គាត់ មាស មុត បានសំអាងថា អ.ប.ជ ត្រូវប្រកាសថា ដីកាដំណោះស្រាយទាំងពីរនេះត្រូវចាត់ទុកថាជាមោឃៈ ដូច្នោះហើយសំណុំរឿងនីមួយៗនោះ ត្រូវផ្ញើទៅឲ្យ ស.ច.ស ឬយកល្អ គឺត្រូវពិនិត្យ សំណុំរឿងនោះដោយខ្លួនឯង (*សូមមើល* ឯកសារ **D266/19 & D267/24** សំណើសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១២, ២២-៣៣, ៤៥-៤៧) បែរជាឥឡូវនេះគាត់អះអាងថា ជម្រើសទាំងពីរនេះគឺ “មិនអាចអនុវត្តទៅបានទេ ឬ មិនអាចទៅរួចឡើយ” (*សូមមើល* ឯកសារ **D267/27** សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣-៣៩, ៥១)។

[43] ឯកសារ **D266/19 & D267/24** សំណើសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១១-១២ *ដោយបានលើកឡើងពី* ឯកសារ **D266/18.2 & D267/23.2** ប្រតិចារឹកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោងៈ ១១.២៦.២៦-១១.៤០.៥៥, ១១.៥៩.១៤-១២.០៣.១៧។ ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៨, ១០, ៣២-៧២។

អ.វ.ត.ក[44] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[45] និងវិធានផ្ទៃក្នុង[46] ជាពិសេសវិធាន ២១ ដូច្នេះត្រូវបានការពារ។ ប្រសិនបើអង្គជំនុំជម្រះនេះកំណត់ថា វាចាំបាច់ត្រូវពន្យល់លើការចេញនេះ និងអានុភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយពីរក្នុងរឿងក្តី ០០៣ ម្ល៉េះខ្លួននឹងប្រាកដជាធ្វើដូច្នោះហើយ។

18. ការអះអាងរបស់ មាស មុត ថា សេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ ពេលនេះ "លើកឡើងអំពីលទ្ធភាពនៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចជំទាស់តវ៉ាបាន លងបន្លាច [គាត់] ជារៀងរហូត"[47] ហេតុដូច្នេះចាំបាច់ត្រូវមានការផ្អាកជាអចិន្ត្រៃយ៍នៃសំណុំរឿង ០០៣ លុះត្រាតែចៅក្រម អ.ប.ជ អាចឈានទៅដល់ការមូលមតិគ្នាជាឯកច្ឆន្ទ[48] គឺទាំងមិនត្រឹមត្រូវតាមច្បាប់ និងជាការទាយស្មានទាំងស្រុង។ ការប្តូរលទ្ធផលអនាគតទាំងអស់នៃសំណុំរឿង ០០៣ ដូចដែល មាស មុត ប្រើពាក្យនោះគឺជា"លទ្ធភាព"[49]។ កិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤/២ *មិនទាន់* បានបិទបញ្ចប់នៅឡើយទេ ហើយបច្ចុប្បន្ននេះកំពុងស្ថិតនៅចំពោះមុខ អ.ជ.ត.ក[50]។ ដូច្នេះ វាជារឿងឆាប់ពេកសម្រាប់ការថ្លែងក្នុងលក្ខណៈចាត់ថ្នាក់របស់ មាស មុត ថា "មិនមានលទ្ធភាពដែលថា [អ.ជ.ស.ដ] ឬ [អ.ជ.ត.ក] អាចធ្វើការត្រួតពិនិត្យដើម្បីដោះស្រាយការជាប់គាំងផ្នែកនីតិវិធី" នៅក្នុងករណីណាមួយនោះ[51]។ តាមពិត ការទាយស្មានដែលតម្រូវឲ្យឈានទៅដល់ការសន្និដ្ឋាននេះគឺមានពីរយ៉ាង៖ វាតម្រូវឲ្យ អ.ប.ជ ធ្វើសមត្តិកម្មមិនត្រឹមតែចំពោះលទ្ធផលនៃសំណុំរឿង០០៤/២ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះដំណើរការទៅមុខនៃសំណុំរឿង ០០៣ ផងដែរ ក្រោយពេលដែល

---

[44] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹង ការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

[45] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានធ្វើវិសោធនកម្ម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)។

[46] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២), ១៣(១)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី, ៣៥ថ្មី។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[47] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ ទំព័រ ១។

[48] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤៦, ៥២។

[49] *សូមមើលបន្ថែមខាងក្នុង* កថាខណ្ឌ ២៧-៣១។

[50] *សូមមើលខាងលើ* កថាខណ្ឌ១១។

[51] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ ចំណងជើងលេខ III.គ។ *សូមមើលផងដែរ* កថាខណ្ឌ ៤០-៤៣, ៥១។

ខ្លួនបានចេញសេចក្ដីសម្រេចរបស់ខ្លួន។ អ.ប.ជ បានបញ្ជាក់នៅក្នុងឱកាសជាច្រើនថា ខ្លួនមិនចេញសេចក្ដីសម្រេចលើបញ្ហាបែបសមត្ថកម្មទេ[52]។

19. ស.ព.អ មិនមានចេតនាតវ៉ាក្ដីលើបណ្ដឹងសាទុក្ខសំណុំរឿង ០០៤/២ របស់គាត់ទៅកាន់ អ.ជ.ត.ក ក្នុងបរិបទនៃចម្លើយតបនេះទេ ការសម្រេចចុងក្រោយ គឺជាបញ្ហាសម្រាប់ អ.ជ.ត.ក ដែលត្រូវសម្រេច មិនមែនជាសិទ្ធិបុព្វក្រ័យរបស់ មាស មុត ទេ។ ទោះជាយ៉ាងណា និយាយដោយសង្ខេប វាមិនត្រឹមត្រូវទាល់តែសោះដែលថា អ.ជ.ត.ក "មិនមានយុត្តាធិការក្នុងការសម្រេច" ពីព្រោះសេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ មិនមែនជា "ដីកាសម្រេចដែលមានអានុភាព បិទបញ្ចប់កិច្ចដំណើរការនីតិវិធី"សម្រាប់គោលបំណងនៃវិធាន ១០៤(៤)[53]ទេ។ ភាពនៅស្ងៀមរបស់ អ.ជ.ស.ដ ក្រោយពេលត្រូវបានប្ដឹងឱ្យទទួលយកនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលបានបញ្ចប់ក្នុងសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ និងការបង្វិលសារណារបស់ភាគីត្រឡប់មកភាគីដើម[54] បង្កើតបានជា "សេចក្ដីសម្រេច" មួយ ដែលផ្ដល់លទ្ធភាពឱ្យមានការប្ដឹងសាទុក្ខទៅកាន់ អ.ជ.ត.ក។ យុត្តិសាស្ត្ររបស់ អ.ជ.ត.ក និង អ.ជ.ស.ដ រួមទាំងសេចក្ដីសម្រេចលើបណ្ដឹឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹង "ការបដិសេធតាមការសន្មត់" នៃពាក្យសុំរបស់គាត់[55] បញ្ជាក់ច្បាស់ថា

---

[52] *សូមមើល ឧទា.* **D158/1** សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៤។ សំណុំរឿង០០៤/២-ឯកសារ **D208/1/1/2** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកា សម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៨ និងការដកស្រង់ខាងក្នុងនោះ។

[53] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

[54] *សូមមើល* សំណុំរឿង០០៤/២-**E004/2/1** បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ជូនទៅ អ.ជ.ត.ក កថាខណ្ឌ ២៩-៣០។

[55] *សូមមើល ឧទា.* ឯកសារ **D87/2/2** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១០-១១។ ឯកសារ **D120/1/1/2** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ចំពោះញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ៧-៨ (ដោយការរំលឹកឡើងវិញថា អនុលោមតាមវិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង អ.ប.ជ មានយុត្តាធិការនឹងស្ដាប់នូវបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្ដីសម្រេច" ឬ "ដីកាបង្គាប់" ដែលបានចេញដោយ ស.ច.ស ប៉ុន្តែថា នៅក្នុងកាលៈទេសៈមួយចំនួន ការមិនចាត់ការរបស់ ស.ច.ស នឹងបណ្ដាលឱ្យមានការបដិសេធតាមការសន្មត ដែលតម្រូវឱ្យមានអន្តរាគមន៍របស់ អ.ប.ជ ដើម្បីរាំងការបាត់បង់សិទ្ធិរបស់ភាគីអ្នកប្ដឹង)។

ភាពនៅស្មៀមរបស់អង្គជំនុំជម្រះដែលមានអានុភាពជាសេចក្ដីសម្រេច អាចប្ដឹងសាទុក្ខបាន[56]។ នៅក្នុងសំណុំរឿង ០០៤/២ អ.ជ.ស.ដ បានរំលត់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អោ អាន ជាធរមាន ដោយមិនបានឈានដល់ដំណាក់កាលសាលក្រម ដែលធ្វើឱ្យបញ្ហានេះស្ថិតក្រោមការប្ដឹងសាទុក្ខភ្លាមៗអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង[57]។ ការអះអាងរបស់ មាស មុត ថា អ.ជ.ត.ក នឹងបែកសំឡេងជាផ្នែកខាងចៅក្រមជាតិ និងអន្តរជាតិនោះ[58] គឺគ្រាន់តែជាទាយស្មានតែប៉ុណ្ណោះ។

---

[56] *សូមមើល ឧទា.* សំណុំរឿង០០២-ឯកសារ **E284/4/8** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ "សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី លើកទីពីរ" កថាខណ្ឌ ២១-២៦ (អ.ជ.ត.ក បានកត់សម្គាល់ថា អ.ជ.ស.ដ ខកខានមិនបានផ្ដល់នូវផែនការ ឬព័ត៌មានជាក់ស្ដែង ណាមួយទាក់ទងនឹងសំណុំរឿងជាបន្តបន្ទាប់ទៀតដែលត្រូវធ្វើសវនការនៅក្នុងដំណើរការនៃសំណុំរឿង០០២ ហើយផងដែរ ក៏មិនព្រមធ្វើការដោះស្រាយបញ្ហាណាមួយ ថាតើអាចនឹងត្រូវដំណើរការសវនាការជាបន្តបន្ទាប់យ៉ាងដូចម្ដេច។ អ.ជ.ត.ក បាន សម្រេចថា ការណ៍នេះ *តាមព្រឹត្តន័យ* នឹងបណ្ដាលឱ្យមានការជាប់គាំងកិច្ចដំណើរការនីតិវិធីដែលមិនបានធ្វើតាមការសន្យា ជាក់ស្ដែងតទៅទៀតឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យបានឈានដល់នូវការវិនិច្ឆ័យលើអង្គសេចក្ដីសម្រាប់ផ្នែកនៃការចោទប្រកាន់ដែល នៅសេសសល់ក្នុងដីកាដំណោះស្រាយ។ បណ្ដឹងឧទ្ធរណ៍នេះត្រូវបានរកឃើញថា អាចទទួលយកបាន តាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង)។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **A189/I/8** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារីទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ២២-២៤ (ដោយរកឃើញថាការខកខានរបស់ ស.ច.ស មិនបានសម្រេចឱ្យបានឆាប់រហ័សនៅលើសំណើរបស់មេធាវីការពារក្ដី នៅក្នុងកាលៈទេសៈដែលមានការពន្យារពេលមួយនៅក្នុងការធ្វើសេចក្ដីសម្រេចនេះ បានដកហូតលទ្ធភាពរបស់ជនជាប់ចោទក្នុងការបានមកនូវផលប្រយោជន៍ដែលគាត់បានស្វែងរក នាំឱ្យមានការបដិសេធតាមការសន្មតនៅក្នុងការអនុវត្ត ដែលរឿងនេះអាចប្ដឹងឧទ្ធរណ៍បាន)។ សំណុំរឿង០០៤/២-ឯកសារ **A117/2/2** សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើលើកទីបួនរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[57] សំណុំរឿង ០០២-ឯកសារ **E284/4/8** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ កថាខណ្ឌ ២១។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **E138/1/7** សេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធ") កថាខណ្ឌ ១៥។ សំណុំរឿង០០២-ឯកសារ **E163/5/1/13** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, កថាខណ្ឌ ២២ ("[អ.ជ.ត.ក] រំឭកថា សិទ្ធិប្ដឹងសាទុក្ខដែលមានចែង...នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយមិនទាន់ ចេញសាលក្រម ដូច្នេះទើបភាគីមិនមានឱកាសដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម")។ សំណុំរឿង០០២-ឯកសារ **E301/9/1/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលា ដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២ ចុះថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០១៤ កថាខណ្ឌ ១៧។

[58] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

20. សំណើរបស់ មាស មុត ដែលថា អ.ប.ជ ធ្វើសេចក្ដីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០៣ ផ្អែកលើសកម្មភាពរបស់អង្គជំនុំជម្រះផ្សេងទៀតក្នុងរឿងក្ដីផ្សេងនោះ គឺជាការប៉ុនប៉ងខុសច្បាប់ដើម្បីកំហិតឯករាជ្យភាពតុលាការរបស់ អ.ប.ជ ដែលត្រូវបានធានាដោយក្របខណ្ឌច្បាប់ អ.វ.ត.ក[59] និង រដ្ឋធម្មនុញ្ញកម្ពុជា[60]។ ដូច្នេះ ការទទួលយកសារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននេះ គឺមិនអនុញ្ញាតទេ។ សំណើរបស់ មាស មុត ឲ្យមានការមូលមតិគ្នាជាឯកច្ឆ័ន្ទក្នុងចំណោមចៅក្រម អ.ប.ជ[61] ក៏មិនត្រឹមត្រូវដូចគ្នាដែរ។ ខណៈដែលចៅក្រមត្រូវបាន*លើកទឹកចិត្ត*ឲ្យធ្វើការឆ្ពោះទៅរកការមូលមតិគ្នាជាឯកច្ឆ័ន្ទដោយកិច្ចព្រមព្រៀង អ.វ.ត.ក[62] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[63]ក្ដី ក៏បទប្បញ្ញត្តិដូចគ្នាទាំងអស់នេះទទួលស្គាល់ថា ការមូលមតិគ្នាជាឯកច្ឆ័ន្ទមិនជាលក្ខខណ្ឌតម្រូវទេ និងអាចធ្វើមិនបានផងដែរ។

21. ការទទួលយកសារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត បន្ថែមលើសំណើសុំការបញ្ជាក់បំភ្លឺ អាចនឹងមានការពន្យារពេល*ច្រើន* ចំពោះការសម្រេចសេចក្ដីរបស់ អ.ប.ជ ក្នុងរឿងក្ដី ០០៣។ មាស មុត អះអាងឥតលាក់លៀមថា ការណ៍នេះ "នឹងមិនបង្កព្យសនកម្មដល់ភាគីណាមួយឡើយ ហើយក៏មិនប៉ះពាល់ដោយមិនត្រឹមត្រូវដល់ក្របខណ្ឌពេលវេលារបស់ [អ.ប.ជ] ក្នុងការសម្រេចសេចក្ដីលើបណ្ដឹងឧទ្ធរណ៍ខ្មែរ ក្នុងរឿងក្ដី ០០៣ ដែរ"[64] ដោយសារ អ.ប.ជ មិនរំពឹងថា នឹងចេញសេចក្ដីសម្រេចរបស់ខ្លួនទេ រហូតដល់ត្រីមាសទីបីនៃឆ្នាំ២០២០។ ដោយយោងទៅលើដំណាក់កាលច្រើននៃវិវាទកម្មដែលបានព្យាករណ៍ដោយសំណើសុំការបញ្ជាក់បំភ្លឺនោះ[65] ឥឡូវនេះសារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ ដែលរួមបញ្ចូលទាំងសំណើមួយផ្សេងទៀតសុំឲ្យមានសវនាការផ្ទាល់មាត់ផងនោះ[66] ការអះអាងរបស់ មាស មុត នៅតែគ្មានមូលដ្ឋាន។

---

[59] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣)។ ច្បាប់ អ.វ.ត.ក មាត្រា ១០ថ្មី, ១២។

[60] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុមតិនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៥១ ("អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ") មាត្រា១២៨ ("អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ") មាត្រា១២៩ ("មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្ដី") មាត្រា១៣០ ("គ្មានអង្គការណាមួយ នៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ")។

[61] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៦, ៥២។

[62] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៤។

[63] ច្បាប់ អ.វ.ត.ក មាត្រា ១៤ថ្មី។

[64] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ ទំព័រ ១។

[65] *សូមមើល* ឯកសារ **D266/20** & **D267/25** ចម្លើយតបរបស់ ស.ព.អ លើការសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១០។

[66] ឯកសារ **D267/27** សារណាបន្ថែមលើណ្ដឹងឧទ្ធរណ៍ ទំព័រ ១។

## *អង្គសេចក្តី*

## ក. អ.ប.ជ មិនត្រូវបានតម្រូវឲ្យច្រានចោលដីកាដំណោះស្រាយទាំងពីរនៃសំណុំរឿង ០០៣ ទុកជាមោឃៈនោះទេ

22. ការអះអាងរបស់ មាស មុត ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់នៃរឿងក្តី ០០៣ ទាំងពីរនេះ ត្រូវតែទុកជាមោឃៈ ប្រសិនបើ អ.ប.ជ ដូចដែលខ្លួនបានធ្វើនៅក្នុងសំណុំរឿង០០៤/២[67] រកឃើញថា *ការចេញ* ដីកាដំណោះស្រាយផ្ទុយគ្នាគឺជារឿងខុសច្បាប់ នោះវាត្រូវបានភូតភរដោយសេចក្តីពិចារណានៃសំណុំរឿង០០៤/២ ខ្លួនវាផ្ទាល់។ អង្គហេតុដែលថា ចៅក្រមទាំងប្រាំនៃ អ.ប.ជ បានពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយក្រោយពេលធ្វើការកំណត់ថា *ការចេញ* ដីកាដំណោះស្រាយពីរខ្វែងគ្នាគឺខុសច្បាប់ គឺជាសេចក្តីសម្រេច*ជាឯកច្ឆ័ន្ទ* និងច្បាស់លាស់របស់ អ.ប.ជ ថា កំហុសរបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") *មិន* ធ្វើឲ្យដីកាដំណោះស្រាយទាំងនោះទៅជាមោឃៈដោយស្វ័យប្រវត្តិឡើយ[68]។

23. ប្រសិនបើ ដីកាដំណោះស្រាយទាំងពីរមិនមានសុពលភាពជាស្វ័យប្រវត្តិស្របតាមក្របខណ្ឌច្បាប់ អ.វ.ត.ក នោះ ចៅក្រមទាំងប្រាំមុខជាបាន (i) ប្រើ "សិទ្ធិអំណាចត្រួតពិនិត្យជាពិសេស"[69] និង "អនុវត្តសិទ្ធិអំណាចពិនិត្យយ៉ាងទូលំទូលាយ *ដើម្បីស្តារនីត្យានុកូលភាព និងការដោះស្រាយចំពោះកំហុសផ្នែកនីតិវិធី* ដែលបង្កឡើងដោយសកម្មភាពមិនស្របច្បាប់របស់ [ស.ច.ស] នៅក្នុងសំណុំរឿងនេះហើយ"[70] (ii) បញ្ជាក់យ៉ាងច្បាស់ថា "ផលប៉ះពាល់" នៃការរកឃើញរបស់ពួកគេលើ *ការចេញ* ដីកាដំណោះស្រាយខ្វែងគ្នា ត្រូវបានបានដោះស្រាយនៅក្នុងមតិយោបល់ដាច់ដោយឡែករបស់ខ្លួន[71] ឬ (iii) បានពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយ[72]។ តាមពិត ទាំងចៅក្រម

---

[67] *សូមមើលខាងលើ* កថាខណ្ឌ ៧។

[68] *ផ្ទុយពី* ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦-៣២។

[69] សំណុំរឿង០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១២៤ (ជាឯកច្ឆ័ន្ទ)។

[70] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កំណត់សម្គាល់ ជើងទំព័រលេខ ៥៩ (សង្កត់ន័យបន្ថែម) (ជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* កថាខណ្ឌ ៤៧ (ជាឯកច្ឆ័ន្ទ) ["អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អំណាចក្នុងការ ត្រួតពិនិត្យរបស់ខ្លួនជាសភាស៊ើបសួរទីពីរ អាចរួមមាន (i) អំណាចរបស់សភាស៊ើបសួរក្នុងការបោសសម្អាតភាពមិនប្រក្រតីនៅ ក្នុងនីតិវិធីដែលខ្លួនបានទទួលវិនិច្ឆ័យ មុនពេលបញ្ជូនទៅជំនុំជម្រះ"]។

[71] សំណុំរឿង០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៨៩, ១២៤ (ជាឯកច្ឆ័ន្ទ)។

[72] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, មតិយោបល់របស់ចៅក្រមជាតិ, កថាខណ្ឌ ២០៤-២៩៤ និង មតិយោបល់របស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៣០៣-៦៨៤។

ជាតិ និងទាំងចៅក្រមអន្តរជាតិមិនបានសម្រេចថា ដីកាដំណោះស្រាយ *ទាំងពីរ* ត្រូវបានទុកជាមោឃៈនោះទេ[73]។

24. ការប៉ុនប៉ងរបស់ មាស មុត ក្នុងការពង្រីកវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ឲ្យហួសពីអត្ថន័យធម្មតា និងគោលបំណងរបស់វា ដើម្បីអះអាងថាវិធាននេះធ្វើឲ្យដីកាដំណោះស្រាយពីរខ្វែងគ្នាទៅជាមោឃៈដោយស្វ័យប្រវត្តិនោះ[74] គឺធ្វើឲ្យយល់ច្រឡំដោយមូលហេតុជាច្រើន។ ទីមួយ ភាសាច្បាស់លាស់នៃវិធាន ៦៧(២) ដែលបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[75] បញ្ជាក់យ៉ាងច្បាស់ថា វាមិនអាចអនុវត្តបាននៅក្នុងករណីនេះ៖ វាអនុវត្តបាន *តែ* ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មោឃៈ *តែ* នៅពេលណាដែលខ្លឹមសាររបស់វា មិនមាន "អត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស [...] មានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"។ ជាងនេះទៀត "វិធាននៃការបកស្រាយច្បាប់ស៊ីវិល" ដែល មាស មុត ស្វែងរកជាជំនួយនោះ[76] ប្រើដើម្បីបញ្ជាក់តែអំពីភាពមិនអាចអនុវត្តបានរបស់វាប៉ុណ្ណោះ។ វិធាន ៦៧(២) ដោះស្រាយតែ*ខ្លឹមសារ* នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនកាលៈទេសៈនានានៃការចេញដីកាទេ ហើយ "គោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណង" របស់វា[77] គឺត្រូវធានាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជូនដំណឹងដល់ជនជាប់ចោទអំពីលក្ខណៈ និងបទចោទនៃរឿងក្តីប្រឆាំងនឹងគាត់[78]។ ដោយយោងទៅលើសារសំខាន់ជាមូលដ្ឋាននៃ

[73] ចៅក្រមជាតិបាននិយាយថា ផលប៉ះពាល់គឺថា "ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) [...] ត្រូវតម្កល់ទុកជាបានការ"។ ចៅក្រមអន្តរជាតិបាននិយាយថា ផលប៉ះពាល់គឺថា "ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវមានសុពលភាព"។ *សូមមើល* សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, KH 01634897 (យោបល់របស់ចៅក្រមជាតិ) និងកថាខណ្ឌ ៣២៦ (យោបល់របស់ចៅក្រមអន្តរជាតិ)។

[74] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧-២៩, ៣២។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ២៤៧ ["ប្រសិនបើ[ចៅក្រម] យល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់"]។

[76] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[77] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩ *ដោយបានលើកឡើងពី* **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣១។

[78] *សូមមើល ឧទា.* សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ ឌុច") កថាខណ្ឌ ៤៦-៤៧,៥០។ សំណុំរឿង០០២-ឯកសារ **D97/14/15** & **D97/15/9** & **D97/16/10** &

ការជូនដំណឹងនេះ វិធានរួមបញ្ចូលលក្ខខណ្ឌតម្រូវដែលស្ថិតក្រោមមោឃភាព។ ដូច្នេះ វាបម្រើតែគោលបំណងជាក់លាក់ណាដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ហើយក៏មិនបានលើកឡើង និងមិនមានចេតនា ដូច មាស មុត អះអាងថា រាល់វិការៈផ្នែកនីតិវិធីទាំងអស់នាំឲ្យដីកាដំណោះស្រាយទៅជាមោឃៈនោះឡើយ។ ប្រសិនបើអ្នកធ្វើសេចក្តីព្រៀងមានគោលបំណងដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យណាផ្សេងទៀតនោះ ម្ល៉េះពួកគេបានធ្វើដូច្នោះហើយ។ ជាទូទៅមិនមាន *ចន្លោះប្រហោង* នៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដូចដែល មាស មុត អះអាងទាំងខុសនោះឡើយ[79]។

25. ស្រដៀងគ្នានេះដែរ វិធាន ៧៦(៥) *មិន* បានបង្ហាញថា "ក្របខណ្ឌរបស់ អ.វ.ត.ក តម្រូវថា ដីកាដំណោះស្រាយដែលមានវិការៈផ្នែកនីតិវិធីនៅក្នុងសំណុំរឿង ០០៣ គួរត្រូវបានធ្វើមោឃភាព ហើយត្រូវដកចេញពីសំណុំរឿង"[80]។ ទីមួយ ដូចដែល មាស មុត កត់សម្គាល់[81] អ.ប.ជ បានសម្រេចរួចហើយថា វិធាន ៧៦ - ដែលគ្របដណ្តប់លើនីតិវិធីមោឃភាពសម្រាប់កិច្ចដែលបានធ្វើក្នុងអំឡុងពេលស៊ើបសួរ - មិនអនុវត្តចំពោះដីកាដំណោះស្រាយទេ។ វិធាន ៧៦(២) មិនរាប់បញ្ចូលការដាក់ពាក្យសុំមោឃភាព ក្រោយពេលចេញដីកាដំណោះស្រាយឡើយ ហើយតាមវិធាន ៧៦(៤) អ.ប.ជ អាចមិនទទួលយកពាក្យសុំមោឃភាពដែល "ទាក់ទងនឹងដីកាដែលបើកផ្លូវប្តឹងឧទ្ធរណ៍"[82]។ ក្នុងករណីណាក៏ដោយ មាស មុត បកស្រាយបទប្បញ្ញត្តិខុស[83] ដោយយល់ច្រឡំអំពីវិការៈផ្នែកនីតិវិធីដែលបានចោទប្រកាន់ អមដោយឧទាហរណ៍នានាដែលអង្គជំនុំជម្រះបានពិនិត្យរួចហើយលើពាក្យសុំមោឃភាពដែលមានសំអាងហេតុ[84] និង "សម្រេចទុកជាមោឃៈកិច្ចស៊ើបសួរ"[85]។ ក្នុងការធ្វើដូច្នោះ គាត់ក៏បានមើលរំលងវិធាន ៤៨[86] ផងដែរ ដោយបានបង្ហាញថា

---

**D97/17/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហ ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ៣១-៣២។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥ថ្មី។

[79] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨។

[80] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២, កំណត់សំគាល់ជើងទំព័រ ១៣០។

[81] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧។

[82] ឯកសារ **D158/1** សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាចអនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ១៧-១៨។

[83] ឯកសារ **D267/27** សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍, កំណត់សម្គាល់ជើងទំព័រលេខ ១៣០។

[84] វិធាន ៧៦(១)-(២) នៃវិធានផ្ទៃក្នុង។

[85] វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង។

ក្របខណ្ឌច្បាប់ អ.វ.ត.ក មិនព្យាករណ៍ទុកជាមុននូវរាល់វិការៈផ្នែកនីតិវិធីទាំងអស់ដែលនាំឱ្យសេចក្ដីសម្រេចជាលទ្ធផល ឬ សកម្មភាពមួយទៅជាមោឃៈ*ពីពេលចាប់ផ្ដើម* នោះទេ។ អ.ជ.ត.ក បានសម្រេចថា "ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់ សុទ្ធតែនាំទៅរកការកែប្រែសាលក្រមឡើយ លើកលែងតែកំហុសនោះបណ្ដាលឱ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ""[87]។

26. សរុបមក មាស មុត ខកខានមិនបានកំណត់អត្តសញ្ញាណច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ណាមួយដែលគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ការចេញខុសច្បាប់នៃដីកាដំណោះស្រាយពីរខ្វែងគ្នានាំឱ្យដីកាទាំងពីរនោះទៅជាមោឃៈនោះឡើយ។ ការយោងនានារបស់គាត់ទៅរកឧទាហរណ៍ពីរនៅតុលាការ*ចំពោះកិច្ច* ពេលដែលសេចក្ដីសម្រេចត្រូវបានរកឃើញថាមោឃៈ ដោយសារតែពួកវាត្រូវបានចេញ*ហួសពីសិទ្ធិអំណាចផ្លូវច្បាប់* (ដោយគ្មានសិទ្ធិអំណាចច្បាប់) គឺមិនត្រឹមត្រូវទេ[88]។ ជាក់ស្ដែង ការចេញយ៉ាងហោចណាស់ដីកាដំណោះស្រាយមួយ គឺមិនត្រឹមតែស្ថិតនៅក្នុងអំណាចរបស់ ស.ច.ស ប៉ុណ្ណោះទេ តែវា*ត្រូវបានតម្រូវ*[89] ជាចំណុចដែលសេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២ បានបញ្ជាក់យ៉ាងច្បាស់[90]។

---

[86] វិធាន ៤៨ នៃវិធានផ្ទៃក្នុង ["កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"]។

[87] សំណុំរឿង០០២-ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០០។

[88] ឯកសារ **D267/27** សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ *ដោយលើកឡើងពី Kupreškić និងគូកន* សំណុំរឿង IT-95-16-AR73.3 អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាលើបណ្ដឹងសាទុក្ខដោយ Dragan Papić ប្រឆាំងនឹងសេចក្ដីសម្រេចឱ្យបន្តដំណើរការដោយការបណ្ដេញចេញ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩, កថាខណ្ឌ ១៤។ *Ntuyahaga* សំណុំរឿង ICTR-98-40-T, ចៅក្រម Laïty Kama, Lennart Aspegren និង Navanathem Pillay, សេចក្ដីប្រកាសអំពីចំណុចច្បាប់, ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ១៩៩៩, កថាខណ្ឌ ១៧។

[89] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧។ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៩, ៣៣, ៣៧-៣៨។ សំណុំរឿង០០២-ឯកសារ **D198/1** ដីការបស់ ក.ស.ច.ស សម្រេចលើសំណើសុំឱ្យបំភ្លឺ កថាខណ្ឌ ១០។ សាលាវិនិច្ឆ័យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៦-៩១.៤៤២ ["Le juge d'instruction avait l'obligation d'instruire, puis de statuer par une ordonnance de règlement sur l'ensemble des faits" […] "Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi"។ ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបសួរមាន កាតព្វកិច្ចត្រូវស៊ើបអង្កេត ហើយបន្ទាប់មកត្រូវចេញដីកាគ្របដណ្ដប់លើគ្រប់អង្គហេតុទាំងអស់។ […] ចៅក្រមត្រូវមានកាតព្វកិច្ចប្រកាសគ្រប់អង្គហេតុទាំងអស់ដែលគាត់ត្រូវបានគេប្ដឹងឱ្យទទួលយកជាទៀងទាត់"។ សាលាវិនិច្ឆ័យ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៤ លេខ ០៣-៨៥.៩៨៣។

[90] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១០៥, ១២១-១២៤ (ជាឯកច្ឆ័ន្ទ)។

## ខ. ការជាប់គាំងផ្នែកនីតិវិធីក្នុងរឿងក្តី ០០៣ មិនមែនជៀសមិនរួចនោះទេ

27. ការព្យាករណ៍របស់ មាស មុត អំពីការជាប់គាំងដែលមិនអាចជៀសរួចនៅក្នុងសំណុំរឿង ០០៣ គឺគ្មានមូលដ្ឋានទេ។ ប្រសិនបើពួកគេពឹងផ្អែកលើមូលដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ ចាំបាច់ត្រូវបានទុកជាមោឃៈ បន្ទាប់ពីមានការកំណត់ថាការចេញដីកាពីរជាប់គ្នាៗគឺជារឿងខុសច្បាប់ ដូចបានពិភាក្សារួចហើយនោះ[91] គឺជារឿងខុស។ ហេតុដូច្នេះគ្មានលក្ខខណ្ឌសម្រាប់ឱ្យ អ.ប.ជ បញ្ជូនបញ្ហានេះត្រឡប់ទៅ ស.ច.ស វិញ ឬ ដឹកនាំការត្រួតពិនិត្យ *សាជាថ្មី* ឡើងវិញដោយខ្លួនឯងឡើយ[92]។ ទោះនៅក្នុងករណីណាក៏ដោយ ការវិភាគរបស់ មាស មុត អំពីផលប៉ះពាល់ផ្នែកអនុវត្តចំពោះជម្រើសទាំងពីរ គឺពោរពេញដោយការស្មាន ហើយការអះអាងរបស់គាត់ថា អ.ប.ជ មិនអាចបំពេញកិច្ចបាន ក្នុងពេលគ្មានភាពឯកច្ឆ័ន្ទដែលមានការធានានោះ[93] គឺមានកំហុសជាមូលដ្ឋាន[94]។ អ.ប.ជ បានដឹងអំពីកាតព្វកិច្ចរបស់ខ្លួនទាំងអស់ ដើម្បី "ការពារផលប្រយោជន៍របស់ជនត្រូវចោទ និងធានាអំពីសច្ចភាពផ្លូវច្បាប់" និង "កិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវយុត្តិធម៌ និងគោរពគោលការណ៍តទល់មុខគ្នា"[95] និងដើម្បី "ធានាចំពោះការគ្រប់គ្រងយុត្តិធម៌ឱ្យបានល្អ និងត្រឹមត្រូវយុត្តិធម៌"[96] នៅពេលស្វែងរករបៀបដោះស្រាយឱ្យបានសមស្រប រួមទាំងតម្រូវការចាំបាច់នៃការស្ទាបស្ទង់លើផលប៉ះពាល់ផ្នែកអនុវត្តទាំងអស[97]។

28. លើសពីនេះ មិនមានភាពមិនច្បាស់លាស់ផ្លូវច្បាប់ បានកើតចេញពីសេចក្តីពិចារណារបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/២ ទេ។ ពេលដែល អ.ប.ជ បានកំណត់ថា *ការចេញ* ដីកាដំណោះស្រាយពីរ គឺជារឿងខុសច្បាប់ និងបានពិចារណាអំពីអនុភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗនោះ ភាពមិនច្បាស់លាស់ណាមួយត្រូវបានដកចេញហើយ។ បន្ទាប់ពីនោះ ដូចបានកំណត់ក្នុងសារណា

---

[91] *សូមមើល ខាងលើ,* កថាខណ្ឌ ២២-២៦។

[92] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៣៣-៣៩។

[93] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៣៤។

[94] *សូមមើល ខាងលើ,* កថាខណ្ឌ ២០, ២៨-៣១។

[95] សំណុំរឿង ០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៤៦, ៥១, ៥៤, ៦៨ (ដកស្រង់គ្រង់ កថាខណ្ឌ ៤៦) (ជាឯកច្ឆ័ន្ទ)។

[96] សំណុំរឿង ០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៥១ (ជាឯកច្ឆ័ន្ទ)។

[97] សំណុំរឿង ០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១០០ (ជាឯកច្ឆ័ន្ទ)។

ជាលាយលក្ខណ៍មុនៗរបស់ ស.ព.អ[98] គឺថាដោយសារ អ.ប.ជ មិនអាចរកបាននូវសំឡេងភាគច្រើនលើសលុបដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះគោលជំហរ "ជាស្វ័យប្រវត្តិ និងជាកត្តាកំណត់" ដែលថា "កិច្ចស៊ើបសួរត្រូវបន្ត"[99] ដូចមានចែងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង តម្រូវឱ្យធ្វើចំណាត់ការដើម្បីធ្វើយ៉ាងណាឱ្យសំណុំរឿងនេះបានទៅដល់ការជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ លទ្ធផលនេះគឺជាកាតព្វកិច្ច ទោះបី អ.ប.ជ ដូចក្នុងសំណុំរឿង ០០៤/២ដែរ ខកខានមិនអាចរកបាននូវសេចក្តីសម្រេចមួយដែលមានសំឡេងភាគច្រើនលើសលុប លើសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ក៏ដោយ។

29. ការនេះ គឺដោយសារយើងត្រូវគោរពចំពោះគោលជំហរស្វ័យប្រវត្តិ ដូចបានរៀបរាប់ដោយចៅក្រម អ.ប.ជ នៅទូទាំងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ទាំងមូល រួមទាំងនៅក្រោយពេលបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ ផង។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះនេះ បានធ្វើការសង្កត់ធ្ងន់ជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/២ ថា៖

> គោលការណ៍ជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរស្វ័យប្រវត្តិ មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធពល និងទម្ងន់ពេញទាំងស្រុងរបស់វាដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូលនៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះ ក្លាយទៅជាគ្មានន័យនោះទេ។ ការសម្រេចផ្សេងពីនេះនឹងនាំឱ្យមានលទ្ធផលផ្លូវច្បាប់មួយដែលមិនសមហេតុផលទាល់តែសោះ ដែលជាការរំលោភទៅលើច្បាប់អន្តរជាតិផង និងច្បាប់កម្ពុជាផង[100]។

[98] *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ១៩១-១៩៨។ ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត, កថាខណ្ឌ ១៩-៥០។ ឯកសារ **D266/6** & **D267/11** ការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ៦៧-៧១។

[99] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។

[100] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១១២ (ជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* កថាខណ្ឌ ១១១ ពន្យល់អំពីគោលបំណងនៃគោលជំហរស្វ័យប្រវត្តិគឺដើម្បី "ធានាឱ្យមានយុត្តិធម៌ដោយប្រសិទ្ធិភាព" និង "ដើម្បីបញ្ចៀសនូវភាពជាប់គាំងផ្នែកនីតិវិធីដែលនឹងរំខានដល់ *មានជាអាទិ៍* ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី"។

30. ដូច អ.ប.ជ បានពន្យល់ហើយថា[101] គោលជំហរជាស្វ័យប្រវត្តិនេះ ដកស្រង់ចេញពីមាត្រា ៥(៤) និង មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[102] ដែលបានទទួលដោយទាំងរាជរដ្ឋាភិបាលកម្ពុជា និងទាំង អ.ស.ប និងសរបញ្ជាក់នៅក្នុងមាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[103]។ បទប្បញ្ញត្តិទាំងនេះបង្ហាញឲ្យឃើញអំពីការសម្រេចចិត្តផ្នែកគោលនយោបាយច្បាស់លាស់ថា នៅក្នុងករណីមានការខ្វែងយោបល់គ្នា ស.ច.ស និងសហព្រះរាជអាជ្ញា អាចបំពេញកិច្ចដោយឯករាជ្យ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី ដែលអាច*បញ្ឈប់បាន* ដោយសំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ប.ជ តែប៉ុណ្ណោះ។ ការបកស្រាយនេះត្រូវបានគាំទ្រយ៉ាងពេញទំហឹងដោយភស្តុតាងនៃការបញ្ជាក់យ៉ាងច្បាស់លាស់របស់ អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា នៅពេលពួកគេបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក[104]។ វាក៏ត្រូវបានអនុវត្តស្របគ្នាជាឯកច្ឆ័ន្ទដោយចៅក្រម អ.ជ.ត.ក[105] និង អ.ប.ជ[106] ផងដែរ។ និយាយដោយឡែក អ.ប.ជ ថ្មីៗនេះបានបញ្ជាក់អះអាងថា៖

---

[101] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ៩៣, ១០៧, ១១១, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។

[102] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៥(៤) (តម្រូវថា កិច្ចស៊ើបសួរ*ត្រូវ*ធ្វើបន្ត វៀរលែងតែមាត្រា ៧ ត្រូវបានអនុវត្ត (សង្កត់ន័យដើម)។ មាត្រា ៧(៤) (តម្រូវថា ប្រសិនបើ អ.ប.ជ មិនអាចដោះស្រាយការខ្វែងយោបល់គ្នាតាមរយៈសំឡេងភាគច្រើនលើសលុប កិច្ចស៊ើបសួរ ឬការចោទប្រកាន់*ត្រូវ*បន្តទៀត (សង្កត់ន័យដើម)។

[103] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ២៣ថ្មី ដែលតម្រូវថា ក្នុងករណីមានការខ្វែងយោបល់គ្នារវាង ស.ច.ស ដោយគ្មានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដើម្បីរាំងរាំងដល់ការរីកចម្រើនរបស់វា កិច្ចស៊ើបសួរត្រូវធ្វើបន្ត (សង្កត់ន័យដើម)។

[104] ឯកសារ **D267/4.1.5** លិខិតពីអគ្គលេខាធិការ អ.ស.ប ជូនចំពោះលោកនាយករដ្ឋមន្ត្រី សម្ដេច ហ៊ុន សែន, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២000, កំណត់សំគាល់ភ្ជាប់ជាឧបសម្ព័ន្ធ ពី Hans Corell ជូនអគ្គលេខាធិការ កម្មវត្ថុៈ ការហៅជាបន្ទាន់ពីកម្ពុជា - ជម្រើសផ្សេងៗសម្រាប់ដោះស្រាយលើភាពខុសគ្នារវាងចៅក្រមស៊ើបសួរ/ព្រះរាជអាជ្ញា, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២000, EN 01614369។ ឯកសារ **D181/2.36** សេចក្ដីថ្លែងការណ៍ដោយអគ្គលេខាធិការរង Hans Corell ក្នុងពេលចាកចេញពីភ្នំពេញនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣, ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣, EN 01326112. *សូមមើលផងដែរ* ឯកសារ **D267/10.1.50** David Scheffer នៅក្នុង M. Cherif Bassiouni (ed), "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ,* បោះពុម្ពលើកទី៣ ភាគ III, ឆ្នាំ២០០៨, ទំព័រ ២៤៦។

[105] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា ឌុច") កថាខណ្ឌ ៦៥។

[106] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១០៥-១០៦, ១១៤-១១៧ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង ០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១, កថាខណ្ឌ ២៧៤។ ឯកសារ **D128/1/9** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ, ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦, កថាខណ្ឌ ៣៤។ សំណុំរឿង ០០៤/១-ឯកសារ **D236/1/1/8** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិសុំពិចារណាឡើង

ក្នុងករណីដែល [អ.ប.ជ] មិនអាចសម្រេចបាននូវសំឡេងភាគច្រើនលើសលុប ដើម្បីបោះឆ្នោតដោះស្រាយបញ្ចប់លើការខ្វែងយោបល់គ្នា នោះក្របខណ្ឌច្បាប់ អ.វ.ត.ក ចែងថា បន្ទាប់មកបញ្ហានេះនឹងត្រូវដោះស្រាយតាមគោលជំហរស្វ័យប្រវត្តិដែលចែងថា កិច្ចស៊ើបសួរត្រូវធ្វើបន្ត"[107]។

31. ដូច្នេះ ក្នុងស្ថានភាពនេះ អ.ជ.ស.ដ ត្រូវតែទទួលយកបណ្តឹងនេះ នៅក្រោមវិធាន ៧៧(១៣)(ខ) និង ៧៩(១)[108] នៃវិធានផ្ទៃក្នុង និងត្រូវនាំយកសំណុំរឿងនេះទៅកាន់សវនាការជំនុំជម្រះ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់មិនត្រូវបានកែប្រែក៏ដោយ។ ស្របតាមគោលជំហរស្វ័យប្រវត្តិ វិធាន ៧៧(១៣)(ខ) ឆ្លុះបញ្ចាំងអំពីចេតនានៅក្នុងការអនុវត្តអាណត្តិច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅពេលណាសហព្រះរាជអាជ្ញា ឬ ស.ច.ស មានការខ្វែងយោបល់គ្នាអំពីការរីកចម្រើននៃរឿងក្តីមួយ៖ បើគ្មានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដើម្បីបដិសេធលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ នោះរឿងក្តីនេះត្រូវបន្តទៅកាន់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី។ ដូចបានពន្យល់ខាងលើ[109] ការខកខានរបស់ អ.ជ.ស.ដ ដើម្បីបំពេញកិច្ចនៅក្រោយពេលខ្លួនត្រូវបានប្តឹងឱ្យទទួលយកសំណុំរឿង ០០៤/២ តាមរបៀបនេះ គឺនៅតែជាកម្មវត្ថុនៃវិវាទកម្មនៅចំពោះ អ.ជ.ត.ក ហើយប្រសិនបើមានការព្យាករណ៍ណាមួយអំពីលទ្ធភាពរបស់វា នោះគឺជារឿងឆាប់ពេក។

---

វិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៤, ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥, កថាខណ្ឌ ៣០។ សំណុំរឿង ០០៤/១-ឯកសារ **A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឲ្យរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ១៤។ ឯកសារ **D1/1.3** ការពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១, ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០៩, កថាខណ្ឌ ១៧, ៤៥ (ដែលបានកែតម្រូវនៅក្នុង ឯកសារ **D1/1.2** ការកែតម្រូវលើសេចក្តីដកស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង និង ឧបសម្ព័ន្ធ **II**, ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩)។

[107] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើសំណុំរឿង ០០៤/២, កថាខណ្ឌ ១១៧ (ជាឯកច្ឆ័ន្ទ)។

[108] វិធាន ៧៧(១៣)(ខ) ដែលបានកំណត់ថា គោលជំហរស្វ័យប្រវត្តិ ប្រសិនបើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានតម្កល់តាមបណ្តឹងឧទ្ធរណ៍ នោះ អ.ជ.ស.ដ ត្រូវបានប្តឹងឱ្យទទួលយកដោយផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ វិធាន ៧៩(១) ចែងថា អ.ជ.ស.ដ ត្រូវបានប្តឹងឱ្យទទួលយកដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពី ស.ច.ស ឬ អ.ប.ជ អមជាមួយនឹងវិធាន ១(២) ដែលកំណត់អំពី ស.ច.ស ថា ចៅក្រមទាំងពីររូប ឬ មួយរូបដែលបំពេញកិច្ចរួមគ្នា ឬតែម្នាក់ឯង។

[109] *សូមមើល ខាងលើ,* កថាខណ្ឌ ១១, ១៨-១៩។

## គ. ការផ្អាកជាអចិន្ត្រៃយ៍នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ មិនអាចធ្វើបានឡើយ

32. ការតវ៉ារបស់ មាស មុត ថា "ដរាបណាចៅក្រម អ.ប.ជ អាចផ្តល់សំអាងហេតុរួមនីមួយៗអំពីភាពរីកចម្រើននៃសំណុំរឿង ០០៣"[110] នោះការរំលោភបំពារដំណើរការ[111] នឹងអនុញ្ញាតឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍[112] គឺការភាន់ច្រំ។ ការតវ៉ានេះ (i) ខកខានមិនបានបំពេញតេស្តសាកល្បងផ្លូវច្បាប់ ដើម្បីកំណត់អំពីទឡ្ហីករណ៍សម្រាប់អនុវត្តការផ្អាកជាអចិន្ត្រៃយ៍មួយ ដែលបានពឹងផ្អែកលើការរំលោភបំពានដំណើរការនោះទេ; (ii) ពឹងផ្អែកលើការសន្មតដែលមិនមានអំណះអំណាងផ្លូវច្បាប់ ឬអង្គហេតុជាមូលដ្ឋានគ្រឹះរឹងមាំ; (iii) ត្រូវបានរកឃើញថា ផ្អែកលើការបកស្រាយខុសជាក់ស្តែងអំពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ ច្បាស់ណាស់ថា មាស មុត អំពាវនាវឲ្យប្រើទ្រឹស្តីនៃ "ការរំលោភបំពានដំណើរការ" ដោយសារគាត់បានដឹងថា ក្របខណ្ឌ អ.វ.ត.ក មិនអនុញ្ញាតឲ្យមានការផ្អាកជាអចិន្ត្រៃយ៍នៃកិច្ចដំណើរការនីតិវិធី ដោយផ្អែកលើមូលដ្ឋានណាមួយផ្សេងនោះទេ។ ផ្ទុយពីការតវ៉ារបស់ មាស មុត[113] យុត្តិសាស្ត្ររបស់ អ.ជ.ត.ក និង អ.ជ.ស.ដ គឺច្បាស់ថា ការផ្អាក"ជាអចិន្ត្រៃយ៍" ឬ "ដែលមិនអាចកែប្រែវិញបាន" មានតម្លៃស្មើនឹងការរំលត់កិច្ចដំណើរការនីតិវិធីជាធរមាន[114] បើដូច្នេះ គឺមិនអាចធ្វើបានឡើយ ក្រៅតែអំពីសម្រាប់មូលហេតុច្បាស់លាស់ដូចមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប៉ុណ្ណោះ៖ គឺមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌនិងអាជ្ញាអស់ជំនុំ[115]។ "ការផ្អាក"តែមួយគត់ដែលអាចធ្វើបាននៅក្រោមច្បាប់កម្ពុជា[116]

---

[110] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ៥២ (ន័យដើមបានដកចេញ)។ *សូមមើលផងដែរ* កថាខណ្ឌ៤១, ៤៦។

[111] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៤៤, ៤៩, ៥១។

[112] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, ទំព័រ ១, កថាខណ្ឌ ៤៤-៥២។

[113] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៤៧។

[114] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធិ"), កថាខណ្ឌ ៣៦, ៣៨។ សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1), ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ("សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី"), កថាខណ្ឌ ២២")។

[115] សំណុំរឿង ០០២ -ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធិ, កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ -ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១, កថាខណ្ឌ ១៦-១៧។ *សូមមើលផងដែរ* មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង។

គឺការផ្អាក "មិនមែនអចិន្ត្រៃយ៍" ឬ "ដែលមានលក្ខខណ្ឌ""[117] ដែលនឹងត្រូវបានលើកនៅពេលណាឧបសគ្គចំពោះកិច្ចដំណើរការនីតិវិធីត្រូវបានដកចេញ[118]។

33. ដោយសារវាជាបញ្ហាចំបង ខណៈ អ.ជ.ត.ក[119], អ.ប.ជ[120], អ.ជ.ស.ដ[121] និង ក.ស.ច.ស[122] សុទ្ធតែបានទទួលស្គាល់ថា ទ្រឹស្តីនៃការរំលោភបំពានដំណើរការ *នៅក្នុងកាលៈទេសៈដ៏កំហិតបំផុត* អាចអនុវត្តបាននៅ អ.វ.ត.ក ក្តី តែវា*មិនធ្លាប់* "បានអនុវត្តនៅ អ.វ.ត.ក ដើម្បីផ្អាកកិច្ចដំណើរការនីតិវិធី" ដូច មាស មុត ចោទប្រកាន់ទេ[123]។ តាមពិត មាស មុត បង្ហាញខុសចំពោះករណីមួយដែលគាត់បានលើកយោងដើម្បីគាំទ្រ។ ក្នុងតួរយ៉ាងនោះ ចៅក្រម អ.ប.ជ បានរកឃើញថា "គ្មានបញ្ហានៃការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនត្រូវចោទ ដូចគ្នានឹងទ្រឹស្តីនៃការរំលោភបំពានដែលអាចនឹងត្រូវបានប្រើដើម្បីអំពាវនាវឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីនោះទេ"[124]។

---

[116] *ផ្ទុយនឹង* ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៤៧។

[117] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធិ, កថាខណ្ឌ ៣៦, ៣៨។ *យោង* *Lubanga*, ICC-01/04-01/06-1487, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចស្តីពីការដោះលែង Thomas Lubanga Dyilo", ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌ ៣៣, ៣៦-៣៧, ៨១។

[118] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធិ, កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E138/1/7** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណុំសុំដោះលែងលើកទីមួយរបស់ អៀង ធីរិទ្ធិ, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, កថាខណ្ឌ ១៧ *យោង* មាត្រា ៣១០, ៣៤៣, ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[119] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៣៨៩-៣៩៩។

[120] *សូមមើល ជាឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ១០, ២០-២៨។

[121] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **E39/5** សេចក្តីសម្រេចលើសំណើសុំដោះលែង, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩, កថាខណ្ឌ ១៦, ៣១-៣៧។

[122] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **C3** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧, កថាខណ្ឌ ១២-២១។

[123] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, កថាខណ្ឌ ៤៩ *យោង* សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ១០។

[124] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ៣៩។

34. ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ មាស មុត ខកខានមិនបានលើកតម្កើង ឬបំពេញ "លក្ខខណ្ឌខ្ពស់ជាពិសេស"[125] សម្រាប់ការកំណត់ថាតើ ការរំលោភណាមួយទៅលើសិទ្ធិរបស់សិទ្ធិជនត្រូវចោទ ឬជនជាប់ចោទ អាចនឹងត្រូវបានពិចារណាថាធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះមួយអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍។ទ្រឹស្តីនៃការរំលោភបំពានដំណើរការ បង្កើតឡើងគឺដើម្បីធានាថា "ការរំលោភ*ធ្ងន់ធ្ងរបំផុត* ទៅលើអំពើប្រព្រឹត្តិ ឬនីតិវិធីដែលជាអំពើ *មិនត្រឹមត្រូវ ឬខុសច្បាប់ទាំងស្រុង*មិនត្រូវបានអនុញ្ញាតឱ្យបដិសេធចំពោះសិទ្ធិនៃការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ ដែលបានផ្តល់ឱ្យជនត្រូវចោទ ឬជនជាប់ចោទនៅចំពោះមុខតុលាការណាមួយឡើយ"[126]។ ការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ គឺជា "ឧបាស្រ័យគំហុក"[127] ដែលត្រូវបានអនុញ្ញាតតែនៅពេលណាមានរឿង "គួរឱ្យខ្ពើមរអើម" ឬ "គួរឱ្យស្អប់ខ្ពើម" ដល់ការគ្រប់គ្រងយុត្តិធម៌បើអនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីនៅបន្ត ឬតែនៅពេលណាសិទ្ធិរបស់ជនជាប់ចោទត្រូវបានបំពារបំពាន រហូតដល់ធ្វើឱ្យសិទ្ធិទទួលបានការជំនុំជម្រះដ៏ត្រឹមត្រូវយុត្តិធម៌មិនអាចធ្វើបានប៉ុណ្ណោះ[128]។ សម្រាប់មូលហេតុនេះ មិនមែនឱ្យតែមានការរំលោភច្បាប់

---

[125] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ២៤ *យោង* *Šešelj,* IT-03-67-T, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើសំណើផ្ទាល់មាត់របស់ជនជាប់ចោទ អំពីការរំលោភបំពានដំណើរការ, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០, កថាខណ្ឌ ២២។

[126] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ១០ *យោង* *Barayagwiza*, ICTR-97-19-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា, ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩, កថាខណ្ឌ ៤។

[127] *Lubanga*, ICC-01/04-01/06-2690-Red2, អង្គជំនុំជម្រះសាលាដំបូង I, សាធារណៈ៖ ច្បាប់កោសលុបនៃសេចក្តីសម្រេចលើ "ពាក្យសុំរបស់មេធាវីការពារក្តីដែលស្វែងរកការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍", ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ("សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្នុងរឿងក្តី *Lubanga*"), កថាខណ្ឌ ១៦៥ *យោង* *Lubanga*, ICC-01/04-01/06-2582, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើបន្ទាន់របស់រដ្ឋអាជ្ញាចំពោះវិបរិណាមនៃពេលវេលាកំណត់ដើម្បីបង្ហាញអត្តសញ្ញាណអន្តរការី ១៤៣ ឬ តាមជម្រើសផ្សេង ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីដោយរង់ចាំការពិគ្រោះយោបល់បន្ថែមជាមួយ VWU", ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០ ("សាលដីកាស្តីពីការកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក្នុងរឿងក្តី *Lubanga*"), កថាខណ្ឌ ៥៥។

[128] *សូមមើល ជាឧទាហរណ៍* សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្នុងរឿងក្តី *Lubanga*, កថាខណ្ឌ ២០៣។ *Ntaganda*, ICC-01/04-02/06-1883, អង្គជំនុំជម្រះសាលាដំបូង VI, សាធារណៈ៖ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីដែលមានបុរេនិច្ឆ័យចំពោះអយ្យការ, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៧ ("សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការក្នុងរឿងក្តី *Ntaganda*"), កថាខណ្ឌ ២០។ *Kenyatta*, ICC-01/09-02/11-868-Red, អង្គជំនុំជម្រះសាលាដំបូង V(B), ច្បាប់កោសលុបសម្រាប់សាធារណៈ៖ សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ដោយសារការរំលោភបំពានដំណើរការ, ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ("សេចក្តីសម្រេច

ឬការបំពារបំពានសិទ្ធិជនជាប់ចោទ សុទ្ធតែអាចយកជាយុត្តិកម្មសម្រាប់ការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍នោះទេ[129]។ អង្គជំនុំជម្រះ អ.វ.ត.ក និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតបានបញ្ជាក់យ៉ាងច្បាស់ថា *វៀរលែងតែ* ជនត្រូវចោទបានទទួលរងនូវអំពើថោកទាបធ្ងន់ធ្ងរចំពោះខ្លួន ដូចជា ការប្រព្រឹត្តិដោយអមនុស្សធម៌ ដោយឃោរឃៅ ឬដោយថោកទាប ឬអំពើទារុណកម្ម ឬប្រសិនបើមានការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ខ្លួនផ្សេងទៀតប៉ុណ្ណោះ ទើបអាចថាបានបំពេញតាមតេស្តនេះ[130]។

35. ក្នុងករណីនេះ ការអះអាងដែលគ្មានមូលដ្ឋានរបស់ មាស មុត អំពី"លទ្ធភាព"[131] នៃកិច្ចដំណើរការនីតិវិធីដែលគ្មានដំណោះស្រាយ ប្រសិនបើចៅក្រម អ.ប.ជ ខកខានមិនបានឈានដល់សេចក្តីសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៣ ដែលជាក់ស្តែងគឺជាការខកខានមិនអាចកំណត់ថា សិទ្ធិទទួលការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌មិនត្រូវបានបំពារបំពាន ហើយភាពប្រាកដប្រជាមិនបានឡើងដល់កម្រិតមួយដូចបានតម្រូវ ដែលអនុញ្ញាតឲ្យផ្អាកសំណុំរឿង ០០៣ ជាអចិន្ត្រៃយ៍ឡើយ។ ដូចបានពន្យល់ខាងលើ ភាពជាឯកច្ឆ័ន្ទរបស់តុលាការ មិនមែនជាលក្ខខណ្ឌតម្រូវទេនៅក្រោមក្របខណ្ឌ អ.វ.ត.ក[132] ហើយការខកខានរបស់ អ.ប.ជ ដើម្បីសម្រេចបាននូវភាពជាឯកច្ឆ័ន្ទនៅលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗ មិនប៉ះពាល់ដល់ភាពច្បាស់លាស់ផ្លូវច្បាប់ទេ[133]។

---

អំពីការផ្អាកកិច្ចដំណើរការក្នុងរឿងក្តី *Kenyatta*"), កថាខណ្ឌ ១៤។ *សូមមើលផងដែរ* *Kallon & Kamara,* SCSL-2004-15-AR72(E) & SCSL-2004-15-AR72(E), *Kamara,* SCSL-2004-16-AR72(E), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាសម្រេចលើការតវ៉ាអំពីយុត្តាធិការ៖ ការលើកលែងទោស Lomé Accord, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤, កថាខណ្ឌ ៧៩។

[129] សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្នុងរឿងក្តី *Lubanga*, កថាខណ្ឌ ១៦២, *យោង* សាលដីកាស្តីពីការកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក្នុងរឿងក្តី *Lubanga*"), កថាខណ្ឌ ៣០។ សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការក្នុងរឿងក្តី *Ntaganda*, កថាខណ្ឌ ២២, សេចក្តីសម្រេចអំពីការផ្អាកកិច្ចដំណើរការក្នុងរឿងក្តី *Kenyatta*, កថាខណ្ឌ ១៤។ *Hartmann*, IT-02-54-R77.5, អង្គជំនុំជម្រះដែលបានតែងតាំងជាពិសេស, សំអាងហេតុសម្រាប់សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំផ្អាកកិច្ចដំណើរការនីតិវិធីដោយសារការរំលោភបំពានដំណើរការ, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩, កថាខណ្ឌ ៤-១៣។

[130] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ-**F28** សាលដីកា ឌុច, កថាខណ្ឌ ៣៩៤។ សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ២២-២៤ ២៧-២៨។ *Nikolić*, IT-94-2-AR73, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន, ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ ("សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Nikolić*")។

[131] ឯកសារ **D267/27** បណ្តឹងឧទ្ធរណ៍បន្ថែម, ទំព័រ ១, កថាខណ្ឌ ៤៥។

[132] *សូមមើល ខាងលើ,* កថាខណ្ឌ ២០។

[133] *សូមមើល ខាងលើ,* កថាខណ្ឌ ២៨-៣១។

ការអះអាងរបស់ មាស មុត ថា ការជាប់គាំងផ្នែកនីតិវិធីក្នុងសំណុំរឿង ០០៣ មិនអាចជៀសរួច នោះ គឺមិនត្រឹមត្រូវផង និងជាការស្មានផង[134]។

36. លើសពីនេះកិច្ចដំណើរការនីតិវិធីដែលបានផ្អាកជាអចិន្ត្រៃយ៍"ជាទូទៅមិនសមាមាត្រទេ"[135] ហើយ មាស មុត ខកខានមិនបានបង្ហាញឲ្យឃើញថា វាជាឧបាស្រ័យដែលសមស្របតែមួយគត់នៅទីនេះ នោះទេ។ គាត់មើលរំលងការសម្រេចពីមុនរបស់ អ.ប.ជ ថា ក្នុងការចាត់របៀបអំពីឧបាស្រ័យ ដែលសមស្រប គេត្រូវតែរក្សាឲ្យបាននូវតុល្យភាពដ៏ត្រឹមត្រូវ រវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍សំខាន់ៗរបស់សហគមន៍កម្ពុជា និងអន្តរជាតិ ក្នុងការចោទប្រកាន់បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត[136] តាមការលើកកម្ពស់ការផ្សះផ្សាជាតិដែលមានការធានាថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ មានសំឡេងដ៏មានអត្ថន័យមួយ[137]។ ក្នុងបណ្តឹងឧទ្ធរណ៍ដើមរបស់គាត់ មាស មុត បានទទួលស្គាល់ថា ឧក្រិដ្ឋកម្មទាំងឡាយដែលគាត់ត្រូវបានចោទប្រកាន់ - រួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[138] - គឺជា "ការព្រួយបារម្ភយ៉ាងខ្លាំងរបស់សហគមន៍អន្តរជាតិ"[139]។

37. តាមកាលៈទេសៈនៃសំណុំរឿងនេះ ការផ្អាកជាអចិន្ត្រៃយ៍នៃសំណុំរឿង ០០៣ គឺជារឿងមួយដែលមិនសមាមាត្រទាល់តែសោះ។ តាមពិត គេអាចប្រកែកបានថា មិនសមស្របទាល់តែសោះដែលត្រូវលើកយកការខូចខាតដែល មាស មុត បានចោទប្រកាន់មកដោះស្រាយ ដោយហេតុថា ការលើកលែងចោទប្រកាន់ដែលមិនពាក់ព័ន្ធទៅនឹងអង្គសេចក្តីនៃសំណុំរឿង ០០៣ មិនបានការពារកិត្តិយស មាស មុត ឬ អនុញ្ញាតឲ្យគាត់តវ៉ាចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ដំណោះស្រាយដ៏មានតក្កភាពបំផុតចំពោះកង្វល់របស់ មាស មុត អំពី "ការចោទប្រកាន់ដែលមិនអាចតវ៉ា

---

[134] *សូមមើល ខាងលើ,* កថាខណ្ឌ ១៨-១៩, ២២-៣១។

[135] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កំណត់សំគាល់ជើងទំព័រ ៥២។ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Nikolić*, កថាខណ្ឌ ៣០។

[136] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាលើសំណើរបស់ អៀង ធីរិទ្ធ ស្តីពីការរំលោភនីតិវិធី, កថាខណ្ឌ ២៧ *យោង* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Nikolić*, កថាខណ្ឌ ៣០។

[137] សំណុំរឿង ០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៦៤-៦៥។ កិច្ចព្រមព្រៀង អ.វ.ត..ក, បុព្វកថា។

[138] *សូមមើល ខាងលើ,* កថាខណ្ឌ ៣។

[139] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត, កថាខណ្ឌ ៤៤។

បានដែលមានលក្ខណៈជាអន្តរ[ចំពោះគាត់]"[140] គឺត្រូវទទួលយកសេចក្ដីសម្រេចច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[141] ដើម្បីធ្វើឲ្យសំណុំរឿងនេះដំណើរការទៅជំនុំជម្រះ។

## IV. ឧបាស្រ័យដែលស្នើឡើង

38. សម្រាប់មូលហេតុដូចបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យ អង្គបុរេជំនុំជម្រះ ច្រានចោលបណ្ដឹងឧទ្ធរណ៍បន្ថែមទាំងមូល៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ | **លោកស្រី** Brenda J.HOLLIS<br>**សហព្រះរាជអាជ្ញាអន្តរជាតិ** | ភ្នំពេញ | [signature and stamp: CO-PROSECUTORS CO-PROCUREURS *E.C.C.C*C.E.T.C*] |

[140] ឯកសារ **D267/27** បណ្ដឹងឧទ្ធរណ៍បន្ថែម, ទំព័រ ១, កថាខណ្ឌ ៥០។ *សូមមើលផងដែរ* កថាខណ្ឌ ២៤, ៤៥។

[141] *សូមមើល ខាងលើ*, កថាខណ្ឌ ២៨-៣១។